វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

# ព័ត៌មានសម្រាប់ប្រជាពលរដ្ឋយល់ដឹងអំពីថវិកាឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ឆ្នាំ២០១៧



## តើរដ្ឋាភិបាលបានប្រើប្រាស់ថវិកាជាតិក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុយ៉ាងដូចម្តេច?

ព័ត៌មានសម្រាប់ប្រជាពលរដ្ឋយល់ដឹង អំពីថវិកាឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា (២០១៧)

កាលបរិច្ឆេទបោះពុម្ព៖ ខែធ្នូ ឆ្នាំ២០១៩

បោះពុម្ពដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា កម្មវិធីបរិស្ថាននិងកសិកម្ម

ស្រាវជ្រាវដោយ៖ លោក  ច័ន្ទ សុផល ទីប្រឹក្សាឯករាជ្យ

សម្គាល់៖ ការទទួលស្គាល់កម្មសិទ្ធិបញ្ញារបស់អ្នកស្រាវជ្រាវជាការចាំបាច់ពេលប្រើប្រាស់របាយការណ៍នេះ
ជាឯកសារយោង ។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ខែធ្នូ ឆ្នាំ ២០១៩

# តើព័ត៌មានសម្រាប់ប្រជាពលរដ្ឋយល់ដឹង អំពីថវិកាឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ (២០១៧) ជាអ្វី? ហេតុអ្វីបានជាកម្ពុជាត្រូវមានព័ត៌មាននេះ?




ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាប្រឈមធំបំផុតសម្រាប់ប្រជាជន និងសេដ្ឋកិច្ចកម្ពុជា។ ការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះមូលហេតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុគឺអាស្រ័យលើរបៀបនៃការប្រមូលចំណូល និងចំណាយថវិកាជាតិតាមរយៈផែនការថវិកា។

ដើម្បីធានាថារដ្ឋាភិបាលធ្វើការសម្រេចចិត្តត្រឹមត្រូវលើថវិកាសម្រាប់សកម្មភាពអាកាសធាតុ និងមានទំនួលខុសត្រូវក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀតគួរតែមានឱកាសចូលរួមក្នុងដំណើរការសម្រេចចិត្ត និងតាមដានការចំណាយនៅមូលដ្ឋាន ហើយជំរុញឲ្យស្ថាប័នរដ្ឋាភិបាលទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិកាជាតិ។ ដើម្បីធ្វើដូច្នេះបាន ប្រជាជន និងស្ថាប័នរបស់ពួកគាត់ត្រូវទទួលបានព័ត៌មាន ដែលងាយស្រួលយល់លក្ខណៈលម្អិត ពេញលេញ និងទាន់ពេលវេលា ទាក់ទងនឹងផែនការថវិកាជាតិ។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ធ្វើការផលិត និងបោះពុម្ពរបាយការណ៍នេះ ដើម្បីផ្តល់ជាព័ត៌មានដល់សាធារណជន ថាតើរដ្ឋាភិបាលកំពុងដោះស្រាយការប្រែប្រួលអាកាសធាតុតាមរយៈការប្រើប្រាស់ថវិកាជាតិដោយរបៀបណា? និងដើម្បីផ្តល់ជាគំរូរបាយការណ៍ ដល់ស្ថានប័នរដ្ឋាភិបាលក្នុងការរៀបចំផ្តល់ព័ត៌មានរបៀបនេះប្រចាំឆ្នាំនៅពេលរៀបចំ និងអនុវត្តន៍ថវិកាជាតិ។

របាយការណ៍នេះ ផ្តល់ព័ត៌មានអំពីថវិកាជាតិសម្រាប់ការប្រែប្រួលអាកាសធាតុតាមក្រសួងសំខាន់ៗមួយចំនួន ដោយផ្អែកលើទិន្នន័យបានមកពីច្បាប់ថវិការបស់ប្រទេសកម្ពុជា របាយការណ៍ពិនិត្យការចំណាយសាធារណៈលើការប្រែប្រួលអាកាសធាតុ២០១៧ និងប្រភពព័ត៌មានរបាយការណ៍ផ្សេងទៀតរបស់រដ្ឋាភិបាលកម្ពុជា។

# កម្ពុជាប្រឈមនឹងហានិភ័យចម្បងៗពីការប្រែប្រួលអាកាសធាតុ




**ប្រជាពលរដ្ឋប្រមាណ ១លានខ្នងផ្ទះ** បានទទួលរងគ្រោះពីព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ក្នុងចន្លោះឆ្នាំ ២០០០ ដល់ ២០១៧

ទឹកជំនន់
៧៤៣.៣០១ ខ្នងផ្ទះ

ភាពរាំងស្ងួត
៤២០.០០៨ ហិកតា

ខ្យល់ព្យុះ
១៨០.០០០ ខ្នងផ្ទះ

គ្រោះមហន្តរាយអាកាសធាតុទាំងនេះអាចបំផ្លាញផ្ទះសំបែង និងទ្រព្យសម្បត្តិផ្សេងទៀត ប៉ះពាល់លទ្ធភាពកសិករក្នុងការផលិតស្បៀងអាហារ បង្កើនការរីករាលដាលនៃជំងឺឆ្លង និងគ្រោះថ្នាក់សុខភាពផ្សេងទៀត បណ្តាលឲ្យមានការចំណាយច្រើនក្នុងគ្រួសារ ការប្រកបអាជីវកម្ម និងប៉ះពាល់ការចំណាយរបស់រដ្ឋាភិបាលផងដែរ ហើយអ្វីដែលធ្ងន់ធ្ងរបំផុតគឺការគំរាមកំហែងដល់ប្រជាជន និងសេដ្ឋកិច្ចកម្ពុជា។

# កម្ពុជាប្រឈមនឹងហានិភ័យចម្បងៗពីការប្រែប្រួលអាកាសធាតុ

ប្រសិនបើមិនមានកិច្ចប្រឹងប្រែងជាងមុនដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនោះទេ ចក្ខុវិស័យរបស់ប្រទេសកម្ពុជាដែលចង់ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងលុបបំបាត់ភាពក្រីក្រ គឺប្រឈមនឹងហានិភ័យខ្ពស់ក្នុងការសម្រេចបាន។

## ការប្រឹងប្រែងដើម្បីដោះស្រាយនឹងការប្រែប្រួលអាកាសធាតុក្នុងកម្រិតបច្ចុប្បន្ន ទំនងជាមិនគ្រប់គ្រាន់ទេដើម្បីកាត់បន្ថយការខាតបង់ផលិតផលក្នុងស្រុកសរុប




(ការប៉ាន់ស្មានការខាតបង់លើអត្រាកំណើនសេដ្ឋកិច្ច បណ្ដាលមកពីការប្រែប្រួលអាកាសធាតុ)

ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៃប្រទេសកម្ពុជា

សម្គាល់៖ GDP គឺសំដៅលើតម្លៃសរុបនៃផលិតផល និងសេវាកម្មផ្សេងៗដែលផលិតបាននៅក្នុងប្រទេស។ វាជាវិធានការចម្បងសម្រាប់សុខុមាលភាពសេដ្ឋកិច្ចរបស់ប្រទេស។

# តើរដ្ឋាភិបាលកម្ពុជាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដោយវិធីណា?

រដ្ឋាភិបាលមានតួនាទីចម្បងក្នុងការកាត់បន្ថយមូលហេតុនៃការប្រែប្រួលអាកាសធាតុព្រមទាំងការពារប្រជាជននិងសេដ្ឋកិច្ចឲ្យរួចផុតពីផលប៉ះពាល់អវិជ្ជមានទាំងឡាយ។ ក្នុងប្រទេសកម្ពុជាការបន្សាំនឹងការប្រែប្រួលអាកាសធាតុជាកត្តាអាទិភាពដែលរួមមានវិធានការមួយចំនួនដូចជា ការផ្តល់គ្រាប់ពូជដែលមានលក្ខណៈធន់នឹងភាពរាំងស្ងួតដល់កសិករ ការជួយប្រជាជនក្នុងការសាងសង់លំនៅដ្ឋាន និងស្តារស្ថានភាពគ្រួសារឡើងវិញ បន្ទាប់ពីគ្រោះមហន្តរាយអាកាសធាតុ និងពង្រឹងការព្យាករណ៍អាកាសធាតុ ព្រមទាំងប្រព័ន្ធផ្តល់ព័ត៌មានជាមុនឲ្យបានលឿន ។

ក្នុងផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា រដ្ឋាភិបាលកម្ពុជាបានរៀបចំគោលដៅមួយចំនួនក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

៨ ពង្រឹងកិច្ចសហប្រតិបត្តិការនិងការចូលរួមពេញលេញក្នុងដំណើរការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ថ្នាក់ជាតិ ថ្នាក់តំបន់ និងពិភពលោក

៧ ពង្រឹងក្របខណ្ឌស្ថាប័ន និងសម្របសម្រួលសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ

៦ លើកកម្ពស់ប្រព័ន្ធការពារសង្គមដែលមានភាពបន្សាំ ព្រមទាំងវិធានការដែលមានការចូលរួមក្នុងការកាត់បន្ថយការបាត់បង់ និងការខូចខាតបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

៥ ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹងក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

៤ លើកកម្ពស់ផែនការ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនទាបក្នុងការទ្រទ្រង់ការអភិវឌ្ឍប្រកបដោយចីរភាព

៣ ធានាភាពបន្សាំអាកាសធាតុ នៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ តំបន់ខ្ពង់រាប ជាដើម។)

២ កាត់បន្ថយភាពងាយរងគ្រោះតាមផ្នែក តាមតំបន់ តាមយេនឌ័រ និងហានិភ័យសុខភាពបណ្តាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

១ លើកកម្ពស់ភាពធន់នៃការប្រែប្រួលអាកាសធាតុតាមរយៈការពង្រឹងសុវត្ថិភាពស្បៀង ទឹក និងថាមពល

# តើមានថវិកាជាតិប៉ុន្មានសម្រាប់រដ្ឋាភិបាលក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ?

ថវិកាជាតិសរុបបានកើនឡើងជិតពីរដងចាប់តាំងពីឆ្នាំ២០១៤កន្លងមក ដែលបានផ្តល់ជាមូលនិធិសំខាន់ក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ?
(គិតជាពាន់លានរៀល)




ប្រភព៖ ច្បាប់ថវិកា២០១៤ ដល់ ២០១៩

ចំណាយដែលបានគ្រោងទុក ចំណាយជាក់ស្តែង ចំណាយដែលគាំទ្រដោយដៃគូរអភិវឌ្ឍន៍

# តើរដ្ឋាភិបាលបានចំណាយថវិកាប៉ុន្មានក្នុងឆ្នាំ២០១៧ លើការប្រែប្រួលអាកាសធាតុ?







ចំណាយរបស់រដ្ឋាភិបាលមួយចំនួនគឺផ្តោតទាំងស្រុងលើការប្រែប្រួលអាកាសធាតុ ហើយចំណាយទាំងនោះគឺមិនមានការចាំបាច់ ប្រសិនបើការប្រែប្រួលអាកាសធាតុមិនបានកើតឡើង។ ឧទាហរណ៍ ជាក់ស្តែងនៃចំណាយដែលមានផលប្រយោជន៍សម្រាប់ការប្រែប្រួលអាកាសធាតុ គឺការសាងសង់ទំនប់ទប់ទឹកសមុទ្រក្នុងការការពារសហគមន៍តំបន់ឆ្នេរពីការកើនឡើងនីវ៉ូទឹកសមុទ្រ។

# តើនិន្នាការក្នុងការចំណាយលើការប្រែប្រួលអាកាសធាតុមានលក្ខណៈដូចម្តេច?

ការចំណាយរបស់រដ្ឋាភិបាលដែលផ្តោតទាំងស្រុងលើការប្រែប្រួលអាកាសធាតុនៅមានកម្រិតទាបពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៧
(ចំណាយថវិកាក្នុងស្រុក និងផ្តល់ដោយដៃគូរអភិវឌ្ឍន៍គិតជាពាន់លានរៀល)



# តើថវិកាចំណាយតាមរយៈក្រសួងណាខ្លះ?

ជាងពាក់កណ្តាលនៃការចំណាយថវិកាលើការប្រែប្រួលអាកាសធាតុសរុបក្នុងឆ្នាំ២០១៧ បានទៅក្រសួងពីរសំខាន់



# តើថវិកាត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច?

## ចំណាយលើការប្រែប្រួលអាកាសធាតុច្រើនបំផុតគឺសម្រាប់ប្រព័ន្ធធារាសាស្ត្រ និងសាងសង់ផ្លូវ

### ចំណែកនៃចំណាយលើការប្រែប្រួលអាកាសធាតុសរុប តាមផ្នែកនីមួយៗ



# តើរដ្ឋាភិបាលបានបង្កើនចំណែកនៃការចំណាយរបស់ខ្លួនដែរឬទេ?

ទោះជាប្រទេសកម្ពុជាបានបង្កើនការចំណាយរបស់ខ្លួនលើការប្រែប្រួលអាកាសធាតុ ប៉ុន្តែការពឹងផ្អែកខ្លាំងលើមូលនិធិដៃគូអភិវឌ្ឍន៍ដែលមិនមានស្ថេរភាព អាចមានការគម្រាមកំហែងលើលទ្ធភាពរបស់រដ្ឋាភិបាលក្នុងការដោះស្រាយជាមួយបញ្ហាការប្រែប្រួលអាកាសធាតុ (គិតជាពាន់លានរៀល)



# តើហេតុអ្វីបានជាស្ត្រីមានភាពងាយរងគ្រោះជាងគេចំពោះការប្រែប្រួលអាកាសធាតុ និង តើមានហានិភ័យអ្វីខ្លះដែលពួកគេបានជួបប្រទះ?

- បាត់បង់ប្រាក់ចំណូល
- វិបត្តិបន្ទាប់ពីគ្រោះមហន្តរាយ
- ការទទួលបានការធានារ៉ាប់រង និងឥណទានមានកម្រិត ដូច្នេះមានជម្រើសតិចក្នុងការដោះស្រាយជាមួយគ្រោះមហន្តរាយ និងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ
- ទំនងជាទាក់ទងទៅនឹងការងារក្នុងវិស័យកសិកម្មច្រើនជាង និងវិស័យផ្សេងទៀតដែលងាយរងគ្រោះដោយបញ្ហាអាកាសធាតុ
- បន្ទុកការងារនិងបញ្ហាសុខភាព
- សមត្ថភាពមានកម្រិតក្នុងការធ្វើកសិកម្មចម្រុះ (ពិពិធកម្មកសិកម្ម)



រដ្ឋាភិបាលមិនទាន់បានផ្តល់ព័ត៌មានគ្រប់គ្រាន់នៅឡើយ អំពីការដោះស្រាយតាមរយៈថវិកា ចំពោះភាពងាយរងគ្រោះរបស់ស្ត្រី ដោយសារការប្រែប្រួលអាកាសធាតុ។ ព័ត៌មាននេះសំខាន់ ដោយសារស្ត្រីនិងកុមារ ប្រឈមនឹងហានិភ័យច្រើនជាងគេ ចំពោះផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ។

## តើការចំណាយលើការប្រែប្រួលអាកាសធាតុបាននឹងកំពុងដោះស្រាយបញ្ហាយេនឌ័រដែរឬទេ?




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ CPER ២០១៧

# តើរដ្ឋាភិបាលអាចធ្វើអ្វីខ្លះក្នុងការពង្រឹងការឆ្លើយតបរបស់ខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ?



១

គួរបង្កើនចំណាយសម្រាប់ការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុដោយផ្ទាល់ពីព្រោះកម្ពុជាមានហានិភ័យខ្ពស់ពីការប្រែប្រួលអាកាសធាតុ ។

២

គួរផ្ដល់បច្ចុប្បន្នភាពព័ត៌មានសាមញ្ញជាមួយការបញ្ជ្រាបយេនឌ័រទាក់ទងនឹងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុការបែងចែកថវិកា និងការចំណាយដែលមានប្រយោជន៍មួយចំនួនក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

៣

គួររៀបចំរបាយការណ៍ព័ត៌មានសម្រាប់ប្រជាពលរដ្ឋយល់ដឹងអំពីថវិកាឆ្លើយតបទៅនឹង ការប្រែប្រួលអាកាសធាតុឲ្យបានទៀងទាត់ដែលបង្ហាញពីនីតិវិធីនៃការប្រមូលថវិកាជាតិ និងការចំណាយក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុដោយសរសេរជាភាសាសាមញ្ញ និងមានក្រាហ្វិកដែលប្រជាពលរដ្ឋទូទៅងាយយល់។

៤

ក្រសួងពាក់ព័ន្ធ គួរអនុញ្ញាតឲ្យ អង្គការមិនមែនរដ្ឋាភិបាលមានឱកាសចូលរួមក្នុងការពិភាក្សា ដើម្បីពង្រឹងដំណើរការរៀបចំថវិកាជាតិក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងមូលដ្ឋាន រួមមានទាំងឱកាសក្នុងការចូលរួមក្នុងការសម្រេចចិត្តនិងការពិនិត្យតាមដានការចំណាយនៅថ្នាក់មូលដ្ឋាន។

អាគារលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង១
ខណ្ឌចំការមន ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ៖ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល៖ **info@ngoforum.org.kh**

**www.ngoforum.org.kh**
**/ngoforumoncambodia**
**/thengoforum**
**/user/ngofoncambodia**

បោះពុម្ពផ្សាយដោយ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា
*The NGO Forum on Cambodia*

UNDP

គាំទ្រដោយ

Climate Finance Network

Sweden Sverige

GOVERNANCE OF CLIMATE CHANGE FINANCE TO ENHANCE GENDER EQUALITY IN ASIA PACIFIC
www.CFADE.org